ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា
លេខ: ០៧០/២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃព្រ.ហ ៩កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ការចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្មរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០២០ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) និងផ្សារមូលបត្រកម្ពុជា បានប្រារព្ធពិធីចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្មរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)។ សញ្ញាបណ្ណសាជីវកម្មរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) មានឈ្មោះថា "សញ្ញាបណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា" ជាសញ្ញាបណ្ណមានបុគ្គលធានា ដែលមានទំហំសរុបចំនួន៨០ ប៊ីលានរៀល (ប្រមាណ ២០ លានដុល្លារអាមេរិក) ជាមួយអត្រាគូប៉ុង ៥,៥% ក្នុងមួយឆ្នាំ និងមានឥណប្រតិទានរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៥។

នៅក្នុងពិធីនេះ **ឯកឧត្តម ស៊ូ សុជាតិ** បានលើកឡើងថាក្រុមហ៊ុនអ អិម អេ (ខេមបូឌា) គឺជាក្រុមហ៊ុនឯកជនទីមួយដែលមិនស្ថិតក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។ ឯកឧត្តមបានបន្ថែមទៀតថា ដោយសារកាលៈទេសៈនៃការរីករាលដាលនៃជំងឺកូវីដ១៩នេះធ្វើឱ្យក្រុមហ៊ុនយល់ថា ការធ្វើពិពិធកម្មប្រភពទុនគឺជារឿងសំខាន់ ដោយហេតុតែក្រុមហ៊ុនដែលមានប្រភពទុនតែមួយនឹងធ្វើឱ្យក្រុមហ៊ុនជួបនឹងបញ្ហាប្រឈម។ ដូច្នេះក្នុងស្ថានភាពលំបាកនេះ ការធ្វើពិពិធកម្មប្រភពទុនពីផ្សារមូលបត្រកម្ពុជាជម្រើសដ៏ល្អបំផុត។ បន្ថែមពីលើនេះ **ឯកឧត្តម ហុង សុភ្វារ** អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានលើកឡើងពី កំណើននៃទីផ្សារមូលបត្រ ក្នុងឆ្នាំ២០១៩ ជាមួយនឹងការកើនឡើងនៃចំនួនក្រុមហ៊ុនចុះបញ្ជី ទំហំជួញដូរប្រចាំថ្ងៃ និងតម្លៃនៃភាគហ៊ុន ដែលកត្តាទាំងនេះនឹងជួយប្រែក្លាយទីផ្សារមូលបត្រទៅជាប្រភពទុនដ៏គួរឱ្យទុកចិត្តបាននៃទីផ្សារមូលបត្រ និងឧបករណ៍វិនិយោគដ៏គួរឱ្យចាប់អារម្មណ៍របស់សាធារណជន។ ដោយឡែក **លោក ខន សាំខ** អគ្គនាយកនៃក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ក៏បានលើកឡើងដែរថា ការ

បោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុលនេះមិនត្រឹមតែជាប្រយោជន៍សម្រាប់ក្រុមហ៊ុនផ្ទាល់នោះទេ ប៉ុន្តែវាបានលើកកម្ពស់ និងពង្រីកទីផ្សារមូលបត្រកម្ពុជាផងដែរ។ ការណ៍នេះនឹងញ៉ាំងឱ្យមានជំនឿទុកចិត្ត និងភាពកក់ក្តៅក្នុងការប្រកបធុរកិច្ចនៅក្នុងប្រទេសកម្ពុជាដោយមានទីផ្សារមូលធនអាចផ្តល់ប្រភពទុន និងជាចលករជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង÷
លោក ហៃ លីដេត
ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជី និងផ្តល់ព័ត៌មាន
អ៊ីម៉ែល÷ lideth.hay@csx.com.kh